# Capacity Waivers for Family Home Providers (ការលើកលែងសមត្ថភាពសម្រាប់អ្នកផ្តល់សេវាតាមផ្ទះរបស់គ្រួសារ)



## តើការលើកលែងសមត្ថភាពថែទាំកុមារនៅតាមផ្ទះរបស់គ្រួសារគឺជាអ្វី?

ច្បាប់រដ្ឋ Washington, RCW 43.216.692 អនុញ្ញាតឱ្យអ្នកផ្តល់សេវាថែទាំកុមារនៅតាមផ្ទះរបស់គ្រួសារថែទាំកុមារលើសពី 12 នាក់ដោយមានការលើកលែង DCYF ដែលបានអនុម័តដែលបំពេញបានតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងច្បាប់ WAC 110-300-0358។

## សមត្ថភាពសរុបដែលបានស្នើសុំ

អ្នកផ្តល់សេវាអាចស្នើសុំការលើកលែងសមត្ថភាពដើម្បីបម្រើកុមារលើសពី 12 នាក់ ប៉ុន្តែមិនលើសពី 16 នាក់ឡើយ។

## អាយុរបស់កុមារ

រួមបញ្ចូលអាយុរបស់កុមារវ័យក្មេងបំផុតរហូតដល់កុមារវ័យចាស់បំផុតដែលអ្នកនឹងទទួលយកមកក្នុងសេវាថែទាំ (មិនមែនត្រឹមតែកុមារដែលអ្នកកំពុងមើលថែទាំប៉ុណ្ណោះទេ)។

## កុមារអាយុក្រោមពីរឆ្នាំ

ចំនួនកុមារសរុបដែលអ្នកចង់ចុះឈ្មោះដែលមានអាយុក្រោមពីរឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែងនេះដាក់កំណត់លើកុមារអាយុក្រោមពីរឆ្នាំមិនលើសពីប្រាំមួយនាក់ឡើយ។

## ទាមទារបទពិសោធ

អ្នកត្រូវតែមានបទពិសោធយ៉ាងតិចបីឆ្នាំជាអ្នកផ្តល់សេវាថែទាំកុមារតាមផ្ទះរបស់គ្រួសារដែលមានអាជ្ញាប័ណ្ណ ជានាយកមជ្ឈមណ្ឌល អ្នកគ្រប់គ្រងកម្មវិធី ប្រធានគ្រូ ឬតួនាទីស្រដៀងគ្នា។

## តម្រូវឲ្យមានការអប់រំ/ការបណ្តុះបណ្តាល

ដើម្បីមានសិទ្ធិ អ្នកត្រូវតែមានវិញ្ញាបនបត្រវគ្គខ្លី ឬមានតម្លៃសមមូលពីរដ្ឋ Washington ដែលត្រូវបានផ្ទៀងផ្ទាត់នៅក្នុងប្រព័ន្ធ MERIT។ លើសពីនេះ អ្នកត្រូវតែមានមនុស្សទីពីរលើបុគ្គលិករបស់អ្នកដែលមានវិញ្ញាបនបត្រដំបូង ឬមានតម្លៃសមមូលដែលត្រូវបានផ្ទៀងផ្ទាត់នៅក្នុងប្រព័ន្ធ MERIT។

## លក្ខខណ្ឌតម្រូវនៃការកំណត់តំបន់ទីក្រុង/ខោនធីក្នុងមូលដ្ឋាន៖

ឧទាហរណ៍ (លក្ខខណ្ឌតម្រូវក្នុងមូលដ្ឋាននឹងប្រែប្រួល)៖

- ផ្ទះនឹងតម្រូវឱ្យមានការត្រួតពិនិត្យពីខោនធី ឬក្រុងដើម្បីប្រាកដថាវាត្រូវតាមលក្ខខណ្ឌតម្រូវ
- ប្រព័ន្ធបាញ់ទឹកដែលបានអនុញ្ញាត (ទីក្រុង និងខោនធីភាគច្រើន) *យើងលើកទឹកចិត្តអ្នកឱ្យចាប់ផ្តើមពិនិត្យមើលរឿងនេះ ពីព្រោះថាវានឹងត្រូវការអ្នកម៉ៅការ*
- តម្រូវឲ្យមានឧបករណ៍ចាប់កម្ដៅនៅក្នុងផ្ទះបាយ
- ភ្លើងបំភ្លឺផ្លូវចេញគឺតម្រូវឱ្យបើកដោយស្វ័យប្រវត្តិក្នុងករណីដាច់បង់ថាមពល

## តម្រូវឲ្យមានកន្លែងទំនេរនៅក្នុងផ្ទះ

- 35 ហ្វីតការ៉េក្នុងកុមារម្នាក់ (មិនគិតពីអាយុ) ត្រូវបានទាមទារ ហើយកន្លែងត្រូវតែជាកន្លែងថែទាំកុមារដែលមានអាជ្ញាប័ណ្ណ DCYF រួចហើយ។
- លើសពីនេះទៀត សម្រាប់កុមារម្នាក់ៗដែលមានអាយុក្រោមពីរឆ្នាំដែលស្ថិតនៅក្នុងបន្ទុក អ្នកត្រូវតែមាន 15 ហ្វីតការ៉េបន្ថែមទៀតនៃកន្លែងថែទាំកុមារដែលមានអាជ្ញាប័ណ្ណ DCYF រួចហើយ។
- បុគ្គលិកផ្ដល់អាជ្ញាប័ណ្ណថែទាំកុមារអាចធ្វើការវាស់វែងបាន ដើម្បីធានាថាមានកន្លែងទំនេរគ្រប់គ្រាន់។

## តម្រូវឲ្យមានកន្លែងទំនេរនៅក្រៅផ្ទះ

- 75 ហ្វីតការ៉េក្នុងកុមារម្នាក់ (មិនគិតពីអាយុ) ត្រូវបានទាមទារ ហើយកន្លែងត្រូវតែជាកន្លែងថែទាំកុមារដែលមានអាជ្ញាប័ណ្ណ DCYF រួចហើយ។
- បើអ្នកមិនមានកន្លែងទំនេរនៅខាងក្រៅផ្ទះតាមចំនួនដែលត្រូវការទេ អ្នកអាចដាក់ស្នើផែនការជាលាយលក្ខណ៍អក្សរអំពីរបៀបដែលអ្នកនឹងផ្លាស់កុមារនៅក្នុងផ្នែក *ផែនការផ្គត់ផ្គង់បុគ្គលិក និងការប្រើប្រាស់កន្លែងទំនេរ*។

## តម្រូវឲ្យមានបង្គន់ និងឡាប៉ូ

ត្រូវតែមានបង្គន់មួយ និងឡាប៉ូមួយសម្រាប់រាល់មនុស្ស 15 នាក់ដែលមានអាយុប្រើប្រាស់បន្ទប់ទឹក។ នេះរាប់បញ្ចូលទាំងសមាជិកគ្រួសារ បុគ្គលិក និងកុមារទាំងអស់នៅលើទីតាំង។ បុគ្គលិក និងសមាជិកគ្រួសារអាចចូលប្រើប្រាស់បង្គន់ និងឡាប៉ូក្នុងទីធ្លាដែលគ្មានអាជ្ញាប័ណ្ណបាន ប៉ុន្តែកុមារនៅក្នុងសេវាមើលថែកុមារប្រហែលជាមិនអាចចូលប្រើបានទេ។ DCYF នឹងត្រូវការឱ្យអ្នកកំណត់កន្លែងបង្គន់ និងឡាប៉ូបន្ថែមរបស់អ្នក និងផែនការរបស់អ្នកដើម្បីបំពេញតាមតម្រូវការរបស់បុគ្គលិករបស់អ្នក។ សូមដាក់ស្នើផែនការជាលាយលក្ខណ៍អក្សរអំពីរបៀបដែលអ្នកនឹងគ្រប់គ្រងបង្គន់ និងឡាប៉ូនៅក្នុងផ្នែក *ផែនការផ្គត់ផ្គង់បុគ្គលិក និងការប្រើប្រាស់កន្លែងទំនេរ*។

Washington State Department of
CHILDREN, YOUTH & FAMILIES

## ការផ្ទៀងផ្ទាត់ប្រព័ន្ធលូទឹកស្អុយ

ប្រសិនបើកន្លែងថែទាំកុមារមានលូទឹកស្អុយ ការផ្ទៀងផ្ទាត់ពីផ្នែកសុខភាពសាធារណៈ ឬអ្នកត្រួតពិនិត្យប្រព័ន្ធលូទឹកស្អុយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផ្សេងទៀតគឺតម្រូវឱ្យបង្ហាញថាប្រព័ន្ធរបស់អ្នកមានលទ្ធភាពគ្រប់គ្រងចំនួនមនុស្សសរុបរួមទាំងសមាជិកគ្រួសារ បុគ្គលិក និងសមត្ថភាពកុមារដែលបានស្នើសុំ។

## លក្ខខណ្ឌតម្រូវនៃកម្មវិធី

អ្នកផ្តល់សេវាថែទាំកុមារតាមផ្ទះរបស់គ្រួសារត្រូវតែផ្គត់ផ្គង់របស់របរឲ្យបានគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការរបស់កុមារម្នាក់ៗដែលបានចុះឈ្មោះក្នុងកម្មវិធី៖

- បន្ទប់តូចៗ/កន្លែងទុកដាក់ផ្ទាល់ខ្លួន
- កន្ទេលគេង/កូនគ្រែ
- គ្រែកូនង៉ែត/ទ្រុងដាក់របស់ឲ្យក្មេងលេង/គ្រែចល័តរបស់កូនង៉ែត
- កុំដែលមានកៅអីអង្គុយ
- របស់ក្មេងលេង
- ហ្គេម
- សម្ភារៈសិក្សា
- បរិក្ខារនៅខាងក្រៅផ្ទះ
- សម្ភារផ្សេងទៀតដូចដែលបានរៀបរាប់នៅក្នុងច្បាប់ WAC 110-300

## ការត្រៀមលក្ខណៈទប់ទល់គ្រោះអាសន្ន

ផែនការត្រៀមលក្ខណៈទប់ទល់គ្រោះអាសន្នរបស់អ្នកអាចត្រូវការការធ្វើបច្ចុប្បន្នភាពដើម្បីសម្រួលដល់ចំនួនកុមារដែលខុសគ្នានៅក្នុងសេវាថែទាំ។ ប្រសិនបើការកែប្រែត្រូវបានធ្វើឡើង សូមផ្ញើជូនបុគ្គលិកផ្តល់អាជ្ញាប័ណ្ណថែទាំកុមារនូវផែនការដែលបានធ្វើបច្ចុប្បន្នភាពដើម្បីសុំការអនុម័ត។

## ផែនការផ្គត់ផ្គង់បុគ្គលិក និងការប្រើប្រាស់កន្លែងទំនេរ

នៅក្នុងផ្នែកនេះ អ្នកអាចពន្យល់លម្អិតអំពីសម្ភារៈដែលត្រូវការការបញ្ជាក់បន្ថែម ឬការអនុម័ត ដូចជាបង្គន់ និងឡាប៉ូដែលត្រូវការ របស់លេងនៅខាងក្រៅផ្ទះជាដើម។

## សំណើសុំលើកលែងសមត្ថភាព៖

- ទទួលបានបញ្ជីផ្ទៀងផ្ទាត់ការពិនិត្យលើកលែងសមត្ថភាពថែទាំកុមារនៅផ្ទះរបស់គ្រួសារដែលត្រូវបានអនុម័តដោយទីក្រុង/ខោនធីក្នុងមូលដ្ឋាន៖ **https://www.dcyf.wa.gov/forms?field_number_value=10-019&title=**
- ដាក់ស្នើបញ្ជីផ្ទៀងផ្ទាត់ដែលត្រូវបានអនុម័ត និងទម្រង់បែបបទស្នើសុំលើកលែងសមត្ថភាពតាមរយៈផតថលអ្នកផ្តល់សេវា។

### តើខ្ញុំទាក់ទងអ្នកណា ប្រសិនបើខ្ញុំមានសំណួរ?

សូមទាក់ទងការិយាល័យផ្តល់អាជ្ញាប័ណ្ណថែទាំកុមារក្នុងមូលដ្ឋានរបស់អ្នក ឬអ្នកផ្តល់អាជ្ញាប័ណ្ណថែទាំកុមាររបស់អ្នក។

## តំណភ្ជាប់សំខាន់ៗ

RCW 43.216.692៖ **https://app.leg.wa.gov/rcw/default.aspx?cite=43.216.692#:~:text=The%20department%20may%20waive%20the,not%20more%20than%2012%20children.**

WAC 110-300-0358៖ **https://app.leg.wa.gov/WAC/default.aspx?cite=110-300-0358**

វិញ្ញាបនបត្រវគ្គខ្លី ឬមានតម្លៃសមមូល៖ **https://www.dcyf.wa.gov/services/early-learning-providers/qualifications/child-care-providers**

MERIT៖ **https://apps.dcyf.wa.gov/MERIT**

WAC 110-300៖ **https://app.leg.wa.gov/wac/default.aspx?cite=110-300**

ផែនការត្រៀមលក្ខណៈទប់ទល់គ្រោះអាសន្ន៖ **https://app.leg.wa.gov/WAC/default.aspx?cite=110-300-0470**

ការិយាល័យផ្តល់អាជ្ញាប័ណ្ណថែទាំកុមារ៖ **https://dcyf.wa.gov/find-an-office/el-offices**

## កម្មវិធីអប់រំបឋមវ័យនៅតាមផ្ទះរបស់គ្រួសារ តារាងសមត្ថភាព 13+ ការលើកលែងសមត្ថភាព

*ឯកសារយោង WAC 110-300-0358*

| អាយុ/ក្រុម | សមាមាត្រអតិបរមា | ថាមវន្តក្រុម | ដែនកំណត់កុមារអាយុក្រោម 2 ឆ្នាំ |
|---|---|---|---|
| **2-12 ឆ្នាំ** | **1:8**<br>នៅពេលដែលមានកុមារ 13 នាក់ឡើងទៅនៅក្នុងសេវាថែទាំ នឹងមានបុគ្គលិកយ៉ាងហោចណាស់ពីរនាក់ (រួមទាំងអ្នកទទួលបានអាជ្ញាប័ណ្ណ) | អាយុចម្រុះពី 2 ឆ្នាំដល់ 12 ឆ្នាំ | ហាមកុមារអាយុក្រោម 2 ឆ្នាំ |
| **ចាប់ពីកើតដល់ 12 ឆ្នាំ** | **1:6**<br>នៅពេលដែលមានកុមារ 13 នាក់ឡើងទៅនៅក្នុងសេវាថែទាំ នឹងមានបុគ្គលិកយ៉ាងហោចណាស់បីនាក់ (រួមទាំងអ្នកទទួលបានអាជ្ញាប័ណ្ណ) | យ៉ាងហោចណាស់កុមារពីរនាក់ដែលមានអាយុក្រោមពីរឆ្នាំអាចដើរដោយខ្លួនឯងបាន | 6 |
| | | យ៉ាងហោចណាស់កុមារម្នាក់អាយុក្រោមពីរឆ្នាំអាចដើរដោយខ្លួនឯងបាន | 5 |
| | | នៅពេលដែលគ្មានកុមារអាយុក្រោមពីរឆ្នាំអាចដើរដោយខ្លួនឯងបាន | 4 |

*ប្រសិនបើអ្នកជាបុគ្គលដែលមានពិការភាព ហើយមានការព្រួយបារម្ភអំពីសិទ្ធិរបស់អ្នក ដូចដែលបានផ្តល់នៅក្រោមច្បាប់ការពារជនពិការអាមេរិក សូមមើលការបោះពុម្ពផ្សាយសេចក្តីជូនដំណឹងជាសាធារណៈអំពីការមិនរើសអើង (HR_0012) សម្រាប់ព័ត៌មាន និងការណែនាំបន្ថែមអំពីរបៀបដាក់ពាក្យបណ្តឹងអនឡាញតាមរយៈ* ***www.dcyf.wa.gov/publications-library/HR_0012*****។**

*ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃឯកសារបោះពុម្ពនេះដោយឥតគិតថ្លៃជាទម្រង់ ឬភាសាផ្សេងទៀត សូមទាក់ទងផ្នែកទំនាក់ទំនងមណ្ឌល DCYF តាមរយៈលេខ 1-800-723-4831 ឬអ៊ីមែល* ***communications@dcyf.wa.gov*****។**

DCYF PUBLICATION LIC_0063 CA (01-2025) Cambodian